# បច្ចេកទេសបង្កាត់_ភ្ញាស់កង្កែប




លោក គឹម សុភា អនុប្រធានស្ថានីយ៍ផលិតត្រីពូជទី ១

ទូរស័ព្ទលេខ: ០១២ ១៨០៧៩៦៥

# មាតិកា


១-សេចក្ដីផ្ដើម

២-លក្ខណៈជីវសាស្ត្រ

២-១.ការរស់នៅ

២-២.ការវិវត្តន៍រូបរាង

២-៣.ចរឹកស៊ីចំណី

២-៤.វដ្ដបន្តពូជ

៣-ការថែបំប៉នមេពូជ

៣-១.ការរៀបចំអាងមេពូជ

៣-២.ការជ្រើសរើសមេពូជ

៣-៣.ការស្តុកមេពូជ

៣-៤.ចំណី និងការផ្តល់ចំណី

៤-វិធីសាស្ត្របង្កាត់

៤-១.លក្ខណៈសំគាល់ញី និង ឈ្មោល

៤-២.ចំនួនកង្កែប ញី និង ឈ្មោល ពេលបង្កាត់

៤-៣.ប្រភេទ និង ការប្រើអ័រម៉ូន

៤-៤.របៀបចាក់កង្កែប

៤-៥.ពេលវេលាបង្កាត់

៥-ការថែបំប៉នកូនក្អុក

៥-១.ការថែរក្សាពងកង្កែប

៥-២.ការស្តុកកូនក្អុក

៥-៣.ចំណី និងការផ្តល់ចំណី

៥-៤.ការគ្រប់គ្រង

៦-ការប្រមូលកូនពូជ

# ១‿សេចក្តីផ្តើម

នាបច្ចុប្បន្ននេះ ការធ្វើវារីវប្បកម្ម មានសន្ទុះយ៉ាងខ្លាំងក្លាលើផ្នែក ការចិញ្ចឹមត្រីជាលក្ខណៈកសិករ. ការចិញ្ចឹមត្រីក្នុងស្រះសាលារៀន. ចិញ្ចឹមត្រីក្នុងស្រែ. ការចិញ្ចឹមបង្កងទឹកសាប. ការចិញ្ចឹមកង្កែប...... ។

ដើម្បីលើកកំពស់ការចិញ្ចឹមឱ្យរីកចំរើន និងឆ្ពោះទៅមុខ ក្រសួង ក៏ដូចជា អគ្គនាយកដ្ឋានជលផល ជាពិសេសមន្ត្រីជំនាញបានផ្ទេរបច្ចេកទេស បង្កាត់-ភ្ញាស់ . សំណង់អាងបង្កាត់-ភ្ញាស់ ដល់កសិករតាមតំបន់នានាដល់មូលដ្ឋាន ។ ក្នុងនោះមានមុខវិជ្ជា បច្ចេកទេស បង្កាត់-ភ្ញាស់ ត្រី . បង្កងទឹកសាប និង កង្កែប ។

ក៏ប៉ុន្តែរយះពេលកន្លងមកនេះ ការចិញ្ចឹមកង្កែបដោយទិញពីអ្នកដើររកចាប់ពីវាលស្រែ ក្នុងព្រៃ ដីក្រូងដី ។ ហើយពូជទាំងនេះមិនល្អ ពីព្រោះវាមានរបួសស្នាម ដូចជា បាក់ជើង . ខ្វាក់ផ្នែក. បែកថ្លើម.... កត្តាទាំងនេះដែលបណ្តាលឱ្យការចិញ្ចឹមកង្កែបធម្មជាតិ មានការលំបាក ពុំទទួលបានលទ្ធផលល្អ ។ ដោយឡែកការចិញ្ចឹមកង្កែបដែលទិញចេញពីកសិដ្ឋានផលិតពូជនោះ វាធ្វើឱ្យការចិញ្ចឹមមានលក្ខណៈងាយស្រួល ការប្រើប្រាស់ចំណីមានគ្រប់គ្រន់ ហើយមានរយះពេលចិញ្ចឹមខ្លី គឺ ពីរខែកន្លះ ទៅ ៣ ខែ ប៉ុណ្ណោះ ។

ដូច្នេះដើម្បីធ្វើអោយការចិញ្ចឹមកង្កែបមានការអភិវឌ្ឍន៏ឆាប់រហ័ស និងមានប្រសិទ្ធភាព កើនឡើងនោះ យើងបានលើកយកប្រធានបទស្តីពី **បច្ចេកទេស បង្កាត់‿ភ្ញាស់កង្កែប** ។

# ២_លក្ខណៈជីវសាស្ត្រ

## ២_១.មជ្ឈដ្ឋានរស់នៅ

កង្កែបជាសត្វមួយប្រភេទ រស់នៅក្នុងទឹកផង លើគោកផង ទីកន្លែងងងឹត និង ស្ងប់ស្ងាត់ ។ ការរស់នៅរបស់វាប្រែប្រួលទៅតាមការវិវត្តន៍រូបរាង ដូចជា នៅដំណាក់កាល កូនក្អុក វាត្រូវការរស់នៅក្នុងទឹករាក់ៗ ពីព្រោះពេលនៅជាកូនក្អុក( មានដុះកន្ទុយ) វាមានតែស្រកីសំរាប់ធ្វើការដង្ហើម ហើយចំពោះដល់ដំណាក់ កាលកូនកង្កែបពូជ( គ្មានកន្ទុយ) ការដង្ហើមត្រូវបានជំនួសដោយសួត និងស្បែកវិញ ។

## ២_២.ការវិវត្តន៍រូបរាង

ការវិវត្តន៍មាន៣ ដំណាក់កាល គឺ :

- ដំណាក់កាលពង គឺ ចាប់ពីពងរហូតដល់ញាស់ជាកូនក្អុក
- ដំណាក់កាលកូនក្អុកគឺ ចាប់ពីកូនក្អុករហូតដល់ក្លាយជាកូនពូជ( ចាប់ពីមានកន្ទុយរហូតដល់ដាច់កន្ទុយ)
- ដំណាក់កាលពេញវ័យ  គឺ ចាប់ពី កូនពូជរហូតដល់កង្កែបធំ ( កង្កែបពេញវ័យ) ។

# ការវិវត្តន៍រូបរាង



## ២.៣.ចរិកស៊ីចំណី

កង្កែបក្នុងធម្មជាតិ ចូលចិត្តចំណីណាដែលមានជីវិត ដូចជា មេអំបៅ កណ្ដូប មូស រុយ ជន្លេន មេភ្លៀង កូនខ្យង ខ្ចៅ ក្ដាម និងសត្វល្អិតផ្សេងៗទៀត។ ម្យ៉ាងវិញទៀត កង្កែបជាសត្វដែលមានការអៀនខ្មាស់ ច្រើននៅពេល ដែលមានមនុស្សឈរមើលច្រើន ហើយវាមិនព្រមចេញមកស៊ីចំណីទេ។

តែចំពោះកង្កែបចិញ្ចឹមវិញ វាចូលចិត្តស៊ីនូវ ចំណីដែលមានរសជាតិ ចំណីកែច្នៃ ចំណីឱសុធាហាកម្ម(ចំណីគ្រាប់) ហើយមានសេចក្ដីក្លាហាន នៅពេលយើងផ្ដល់ចំណីម្ដងៗ កង្កែបលោតបក់ចាប់ចំណីស៊ុធម្មតា មិនខ្លាចមនុស្ស ។

## ២.៤.រដូវបន្តពូជ

កង្កែបញី និង កង្កែបឈ្មោលអាយុ ១-២ ឆ្នាំឡើងទៅទើបល្អ មានការបន្តពូជខ្ពស់ និងមានអត្រាញាស់ល្អ ។ ហើយក្នុង១ឆ្នាំ បន្តពូជបាន៣ដង គឺចាប់ផ្ដើមពី ខែ មករា រហូតដល់ ខែ កញ្ញា ពិសេសទៀតក្នុងរដូវមានភ្លៀង ។

កង្កែបញី ១ គ.ក្រ អាចមានគ្រាប់ពងពី ៦០០០-៨០០០ ។

# ៣_ការថែបំប៉នមេពូជ

## ៣_១.ការរៀបចំអាងបំប៉ន

អាងមេពូជត្រូវសាងសង់ទីកន្លែងភ្លឺ ឆ្ងាយពីផ្ទះបន្ទិច ពុំមានសំលេងរំខាន ។ កំរិតទឹកក្នុងអាងគឺ ពាក់កណ្តាល ខ្លួនកង្កែប ។

## ៣_២.ការជ្រើសរើសមេពូជ

-ត្រូវជ្រើសរើសកង្កែបពូជ ដែលមានសុខភាពល្អ និងគ្មានស្នាមរបួស ។

-កង្កែបញី ឈ្មោលពេញវ័យដែលមានអាចបន្តពូជបានអាយុពី ១ ឆ្នាំ ឡើងទៅ ។

-ត្រូវជ្រើសរើសមេពូជឱ្យមានលក្ខណៈប្រហាក់ប្រហែលគ្នា ។

-ត្រូវចាប់ផ្តើមជ្រើសរើសមេពូជមកបំប៉នឱ្យបានល្អ មុនរដូវបន្តពូជរយៈពេល ១ ខែ។

## ៣_៣.ការស្តុកមេពូជ

-ក្រោយពីបានជ្រើសរើសមេពូជ យើងត្រូវដាក់បំប៉នក្នុងអាងផ្សេងៗពីគ្នា ។

-ការស្តុកមេពូជគឺ ចំនួន ៥០ក្បាល/ម$^{២}$ ។

## ៣_៤.ចំណី និងការផ្តល់ចំណី

យើងអាចប្រើ ចំណីគ្រាប់ ឬ ចំណីកែច្នៃ ផ្តល់ ៣ដង/ថ្ងៃ កំរិត៣%នៃទំងន់ដងខ្លួន ( ព្រឹក .ថ្ងៃត្រង់. ល្ងាច ) ។ លាងសំងាតអាង ២ដង/ថ្ងៃ គឺ ពេលព្រឹក និង ពេល ល្ងាច ឱ្យបានមុនការផ្តល់ចំណី ។

# អាងបំប៉នមេពូជ  និង  ចំណី






# ៤.វិធីសាស្ត្របង្កាត់

## ៤.១.លក្ខណសំគាល់កង្កែប ញី និង ឈ្មោល

### ចំពោះកង្កែបឈ្មោល ៖

នៅបាតជើងមុខទាំងពីរ មានដុះសាច់ពកច្រើនរាងគ្រើមៗ ដែលហៅថា បន្ទាបន្តពូជ ។មានចំណុច ខ្មៅពីរ នៅគល់ថ្គាមទាំង សងខាង ហៅថា ថង់សំលេង ។ ពោះតូច និងមានលក្ខណៈរូបរាងតូចជាងកង្កែបញី ។






### ចំពោះកង្កែបញី ៖

នៅបាតជើងមុខទាំងពីរ គ្មានបន្ទាបន្តូច ដូចកង្កែបឈ្មោលទេ ។ជាទូទៅមានពោះធំ និងមានលក្ខណៈទន់ជាងកង្កែបឈ្មោល ហើយ ស្បែកពោះគ្រើមៗ ។ កង្កែបញីមួយអាចពងបានពី ១៥០០-២០០០ ។



## ៤.២.ចំនួនកង្កែប ញី និង ឈ្មោល ពេលបង្កាត់

ប្រើកង្កែបញី ១ក្បាល និង កង្កែបឈ្មោល ១ក្បាលដែរ ។ ក្នុងការបង្កាត់ម្តងៗ យើងប្រើ ១០ គូ ក្នុងផ្ទៃ អាង ២ម$^{២}$ ហើយអាងត្រូវដាក់ទឹកក៏រិត ពាក់កណ្ដាលនៃខ្លួនកង្កែប ។

## ៤.៣.ប្រភេទ និង ការប្រើអ័រម៉ូន

| ប្រភេទអ័រម៉ូន | ក៏រិតថ្នាំ/១គ.ក្រកង្កែបមេ | ផ្សេងៗ |
|---|---|---|
| LRH-A | (LRH-A) +Motium | លាយថ្នាំឱ្យសព្វ |
| Superfact | (Superface)+Motium | លាយថ្នាំឱ្យសព្វ |

ចំពោះកង្កែបឈ្មោល គឺ យើងប្រើថ្នាំតែ ពាក់កណ្ដាលនៃក៏រិតថ្នាំកង្កែបមេ ។

# ប្រភេទអ័រម៉ូន




ប្រភេទអ័រម៉ូន អិល អរ អេក អេ (LRH-A)

ប្រភេទអ័រម៉ូន ស៊ូហ្វឺហ្វាក់ (Superfact)



## ៤.៤.របៀបចាក់កង្កែប

កន្លែងដែលត្រូវចាក់ថ្នាំ គឺនៅត្រង់ជើងខាងមុខ ទាំងកង្កែបញី ទាំងកង្កែបឈ្មោល ។




ការថ្លឹងកង្កែបមុនចាក់ថ្នាំ





ការចាក់ថ្នាំ

## ៤.៥.ពេលវេលាបង្កាត់

យើងត្រូវជ្រើសរើសមេពូជមកដាក់ក្នុងអាងបង្កាត់ឱ្យបានមុន ២ម៉ោង ហើយការអនុវត្តចាក់ថ្នាំនៅម៉ោង ៥ ល្ងាច ។

ប្រភេទអាងបង្កាត់ ភ្លាស់






# ការជ្រើសរើសមេពូជដាក់បង្កាត់ មានទំហំប្រហាក់ប្រហែលគ្នា



ឈ្មោលតូចជាងញី គឺមិនល្អ



ឈ្មោលញីទំហំប៉ុនគ្នា គឺល្អ

# ការដាក់ចំនួនច្រើនគូរ  គឺធ្វើឱ្យឈ្មោលចាប់គូរគ្នាឯង  ឬញីចាប់គូរគ្នាឯង(មិនសមស្រប)



# ៥ ការថែបំប៉នកូនកង្កែប

## ៥.១.ការថែរក្សាពងកង្កែប

ក្រោយរយៈពេលពី ៨-១០ ម៉ោង គឺ ភ្លឺឡើង យើងត្រូវចាប់យកមេពូជចេញ ដោយរក្សាពងកង្កែបក្នុងអាងដដែលរហូតដល់ញាស់ បើអាកាសធាតុក្តៅល្អ ពងកង្កែបចាប់ញាស់ក្នុងរយៈពេលពី ៨-១០ ម៉ោង ហើយបន្តទុកក្នុងអាងឱ្យបានរយៈពេល ពី ២-៣ ថ្ងៃទៀត ទើបផ្ទេរយកទៅដាក់ថែរក្សាក្នុងអាងផ្សេងទៀត ។



# លក្ខណៈពងកង្កែប



ពងកង្កែបទើបទំលាក់

ពងកង្កែបមានការផ្សំកំណើត



## ៥.២.ការស្តុកកូនក្អក

អាងបំប៉នកូនក្អក ស្ថិតនៅទីវាល គ្មានប្រកដំបូល ហើយរក្សាទឹកក្នុងអាងឱ្យបានកំពស់ 0.១ ម (១ តឹក )។ ផ្ទៃអាង ២ម² អាចស្តុកបាន ១000 ទៅ ២000 កូនក្អក/ម² និងផ្ទៃបាតអាងត្រូវមានសភាពរលោង ។

## ៥.៣.ចំណី និងការផ្តល់ចំណី

រយះពេលពី ២-៣ថ្ងៃដំបូង កូនក្អកចេះហែលរកចំណីស៊ី ចំណីពិសេសរបស់វា គឺ ចៃទឹក បណ្តូលពងមាន់ក្រហាមស្ងោរ ត្រូវផ្តល់ចំណីឱ្យបានច្រើនដង/ថ្ងៃ ពីព្រោះបើចំណីមិនគ្រប់គ្រាន់ កូនក្អកនឹងស៊ីគ្នាឯង ធ្វើឱ្យបាត់បង់ច្រើន ។ ចំណី ពេលនេះ ពី ៣0- ៥0 ក្រាម/១000 ក្ប ឬម៉្សៅត្រី ដែលមានប្រូតេអ៊ីន ៤0% ដោយរោយឱ្យសព្វលើ ផ្ទៃទឹក ។

**<u>របៀបផ្តល់ចំណីដូចខាងក្រោម</u>** :

-អាយុពី ២ថ្ងៃរហូតដល់ថ្ងៃទី៧ ផ្តល់ចំណី ចៃទឹក ឬ ពងមាន់ ក៏រិត ៣0-៥0ក្រ/១000កូនក្អក/ថ្ងៃចំនួន៧ដង

-អាយុពី ថ្ងៃទី៨រហូតដល់ថ្ងៃទី១៨ ផ្តល់ចំណី ពងមាន់ និង ម្សៅត្រី ក៏រិត ២0-៤0ក្រ/១000 កូនក្អក/ថ្ងៃ ចំនួន៥-៦ដង ។

-អាយុពីថ្ងៃទី១៩រហូតដល់កូនពូជ(ដាច់កន្ទុយ) ផ្តល់ចំណី ម្សៅត្រី ក៏រិត ៣0ក្រ និងចំណីគ្រាប់មានទំហំ១ម.ម ១00ក្រ/១000 កូនក្អក/ថ្ងៃ ចំនួន៤-៥ដង ។

# អាងបំប៉នកូនក្អូក



កូនក្អូកមានអាយុ ៣ថ្ងៃ



កូនក្អូកមានអាយុ ២២ថ្ងៃ

### ៥.៤.ការគ្រប់គ្រង

រយៈពេលថែបំប៉នកូនក្អុករហូតដល់កូនពូជកង្កែប យើងត្រូវយកចិត្តទុកដាក់ទៅលើដូចជា :

-ត្រូវធ្វើការផ្តល់ចំណីឱ្យបានគ្រប់គ្រាន់ ទៀងទាត់តាមពេលវេលា

-ចំណីត្រូវមានគុណភាពល្អ និងមានកំរិតប្រូតេអ៊ីនត្រឹមត្រូវ

-ផ្លាស់ប្តូរទឹក ២ដង/ថ្ងៃ គឺ ព្រឹក និង ពេលល្ងាច ( មុនការផ្តល់ចំណី)

-ការពារកុំឱ្យទឹកភ្លៀងហូរចូលក្នុងអាងបំប៉នកូនក្អុក ។

## ៦.ការប្រមូលផល

ក្រោយរយៈពេល ២៧-៣០ថ្ងៃ កូនក្អុកបានប្រែរូបទៅជាកូនពូជ ហើយក៏ជាដំណាក់កាលលក់ ឬចែកចាយពូជ ដល់អ្នកចិញ្ចឹមកង្កែបសាច់ ដែលមានទំហំ ១.៥-២ក្រាម/ក្បាល ។


សូមអរគុណ
50kg
HÀ NỘI